# ធាតុចូលសំខាន់ៗ
# លើសេចក្តីព្រាងច្បាប់ថ្មីស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
# របស់ក្រុមការងារថវិកា នៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ

ក្រុមការងារថវិកា គឺជាបណ្តុំនៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ប្រមាណ២០ស្ថាប័នធ្វើការរួមគ្នាដើម្បីលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋ ក្នុងការធ្វើកំណែទzម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជារៀងរាល់ឆ្នាំ យើងបានធ្វើការវិភាគថវិកាជាតិ ពាក់ព័ន្ធវិស័យអាទិភាពសំខាន់ៗដូចជាអប់រំ កុមារ យេនឌ័រ សុខភាព បរិស្ថាន ធនធានធម្មជាតិ ការរៀបចំកិច្ចពិភាក្សា សន្ទនា វេទិកាសាធារណៈ និងការផ្តល់ព័ត៌មានថវិកាជាសាធារណៈនៅក្នុងដំណើរការថវិកាជាតិទាំងមូល។ នៅក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ក្រុមការងារថវិកាជាតិដែលមានវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានចូលរួមជាមួយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីជម្រុញឲ្យកាន់តែមានតម្លាភាពបន្ថែមទៀតក្នុងដំណើរការរៀបចំ និងអនុវត្តថវិកា និងឲ្យមានភាពស៊ីគ្នាកាន់តែប្រសើរឡើងរវាងថវិកាជាតិកម្ពុជាជាមួយនឹងគម្រោងអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ និងការពិនិត្យមើលលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីសវនកម្ម។

ក្រុមការងារយើងខ្ញុំ ធ្លាប់បានធ្វើការសិក្សាវិភាគលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលកំពុងមានជាធរមាន ជាមួយអ្នកជំនាញ និងបានផ្ញើជូនធាតុចូលសំខាន់ៗដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាពេលកន្លងមក។ ក្រោយពីបានទទួលឯកសារសេចក្តីព្រាងច្បាប់ថ្មីស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះរួចមកយើងខ្ញុំបាន ពិនិត្យ និងពិភាក្សាក្នុងចំណោមសមាជិកក្រុមការងារ និងសិក្សាឯកសារច្បាប់ពីបណ្តាប្រទេសផ្សេងៗមួយចំនួនរួមមាន សេរ៉ាឡេអូន ដែលសម្រេចបានជាសេចក្តីថ្លែងគោលជំហរ និងធាតុចូលសំខាន់ៗដូចខាងក្រោមនេះ៖

ជាទូទៅ បើប្រៀបធៀបនឹងច្បាប់បច្ចុប្បន្ន សេចក្តីព្រាងច្បាប់នេះ មានលក្ខណៈលំអិតនិងពេញលេញជាង។ សេចក្តីព្រាងច្បាប់នេះ បានបង្ហាញទិដ្ឋភាពពាក់ព័ន្ធទាំងអស់នៃស្តង់ដារអន្តរជាតិ និងការអនុវត្តល្អបំផុតក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីព្រាងច្បាប់នេះ ផ្តល់អំណាចលើសលប់ដល់ស្ថាប័ននីតិប្រតិបត្តិជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យស្ទើរតែគ្រប់ទិដ្ឋភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សេចក្តីព្រាងច្បាប់នេះ មានកង្វះខាតច្រើនក្នុងការកំណត់ និងគូសបញ្ជាក់អំពីតួនាទី និងមុខងាររបស់ស្ថាប័នត្រួតពិនិត្យ ដូចជារដ្ឋសភា ព្រឹទ្ធសភា និងអាជ្ញាធរសវនកម្មជាតិ។ លើសពីនេះ គោលការណ៍នៃតម្លាភាព និងការពិគ្រោះជាសាធារណៈ ហាក់ដូចជាអវត្តមានស្ទើរតែទាំងស្រុង។

**មតិយោបល់ជាក់លាក់៖**

សេចក្ដីព្រាងច្បាប់នេះ គួរតែរួមបញ្ចូលបទប្បញ្ញត្តិដែលចែងយ៉ាងច្បាស់នូវការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយអត្ថន័យជាមួយអ្នកពាក់ព័ន្ធ រួមមានអង្គការសង្គមស៊ីវិល វិស័យឯកជន យុវជន និងសាធារណៈជនទូទៅក្នុងដំណើរការរៀបចំថវិកានៅថ្នាក់ក្រសួង ស្ថាប័ន ព្រមទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឧទាហរណ៍.

**មាត្រា ៤៩** គួរតែត្រូវបានបន្ថែមកថាខណ្ឌថ្មីមួយ ដោយចែងថា "ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលដទៃទៀត ត្រូវរៀបចំការពិគ្រោះយោបល់ជាសាធារណៈជាប្រចាំជាមួយសាធារណជនទូទៅ ដើម្បីប្រមូលមតិយោបល់ និងធាតុចូលសំខាន់ៗក្នុងការរៀបចំថវិការបស់ស្ថាប័ន ពីប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជន"។

សេចក្ដីព្រាងច្បាប់នេះ គួរតែចែងបន្ថែមអំពីមូលដ្ឋានច្បាប់សម្រាប់តម្លាភាព និងការប្រឹក្សាសាធារណៈ ដោយតម្រូវឱ្យរាជរដ្ឋាភិបាលផ្សព្វផ្សាយព័ត៌មានឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដើម្បីអនុញ្ញាតឱ្យសាធារណជនពិនិត្យពិច័យលើការអនុវត្តគោលនយោបាយសារពើពន្ធ និងស្ថានភាពហិរញ្ញវត្ថុសាធារណៈ។ ឧទាហរណ៍ គួរតែមានមាត្រា ឬបទប្បញ្ញត្តិបន្ថែមស្ដីពីការផ្សព្វផ្សាយជាសាធារណៈនូវសេចក្ដីព្រាងពេញលេញនៃច្បាប់ថវិកាជាតិ និងផ្ដល់វេទិកាសម្រាប់ប្រជាពលរដ្ឋ រដ្ឋសភា ក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីផ្ដល់ធាតុចូល មុនពេលសេចក្ដីព្រាងច្បាប់ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី និងមុនពេលដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីអនុម័ត។ ជាមូលដ្ឋានគ្រឹះតម្លាភាព និងគណនេយ្យភាព គួរមានចំណុចគោលណាមួយសម្រាប់ទទួលមតិត្រឡប់ពីការអនុវត្តន៍ច្បាប់ថវិកាដែលផ្ដល់ឱកាសឲ្យអង្គការសង្គមស៊ីវិល យុវជននិងសាធារណជនបានចូលរួមពិនិត្យមើលការឆ្លើយតបសេវាដល់ប្រជាពលរដ្ឋ។

សេចក្ដីព្រាងច្បាប់នេះក៏គួរចែងផងដែរនូវបទប្បញ្ញត្តិដែលអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង/ឬ រដ្ឋសភា/ព្រឹទ្ធសភាផ្សព្វផ្សាយជាសាធារណៈបានឲ្យទាន់ពេលវេលាត្រូវការ នូវឯកសារពេញលេញអំពីថវិកា ដូចជា៖ សារាចរណែនាំស្ដីពីការរៀបចំសេចក្ដីព្រាងច្បាប់ថវិកា សេចក្ដីព្រាងច្បាប់ថវិកា ច្បាប់ថវិកាដែលបានអនុម័ត ថវិកាសង្ខេប តារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ចប្រចាំខែ របាយការណ៍ប្រចាំឆមាស របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍សវនកម្ម និងបង្កើតយន្តការអាចធ្វើទៅបាន សម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ ត្រួតពិនិត្យការអនុវត្តថវិកា។

**មាត្រា ៧៦, ៧៧, ៧៨, ៩៥ និង ១០០**

មាត្រាទាំងនេះ គួរតែបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ស្ថាប័នត្រួតពិនិត្យ ដូចជារដ្ឋសភា និងព្រឹទ្ធសភា ក្នុងដំណើរការទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងការកសាងថវិកា ការអនុវត្តថវិកា និងការវាយតម្លៃ/សវនកម្ម ព្រមទាំងការអនុម័ត និងការគ្រប់គ្រងបំណុលផងដែរ។

ជាពិសេស យើងខ្ញុំសូមស្នើឱ្យបន្ថែមកថាខណ្ឌមួយទៀតក្នុង**កថាខណ្ឌទី៤ នៃមាត្រា៧៦** ដោយចែងថា « របាយការណ៍សមិទ្ធកម្មដែលភ្ជាប់ជាមួយនូវអនុសាសន៍គួរត្រូវបានត្រួតពិនិត្យ និងសម្រេចដោយគណៈកម្មការទី២ នៃរដ្ឋសភា មុនពេលដែលអនុសាសន៍ទាំងនោះត្រូវដាក់ឲ្យក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់

ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីប្រើប្រាស់ជាធាតុចូលសម្រាប់កែលម្អផែនការសមិទ្ធកម្មនាឆ្នាំបន្ទាប់។»

**មាត្រា ៧៦ កថាខណ្ឌទី ៥** គួរតែត្រូវបានកែសម្រួលដូចតទៅ៖ " ដោយមានការយល់ព្រម ពីគណៈកម្មការទី ២ នៃរដ្ឋសភា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចផ្តួចផ្តើម និងដឹកនាំការវាយតម្លៃតាមការចាំបាច់ និងតាមការជ្រើសរើស ដើម្បីវាស់វែងប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃកម្មវិធីរបស់ក្រសួង ស្ថាប័ន។"

**មាត្រា ៧៧ កថាខណ្ឌទី ១** គួរតែត្រូវបានកែសម្រួល ដោយបន្ថែមនូវខ្លឹមសារដូចតទៅ ៖ «ក្រោមលក្ខខណ្ឌ និងដែនកំណត់នៃសិទ្ធិអំណាចដែលបានផ្តល់ប្រចាំឆ្នាំ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី និងការយល់ព្រមពីរដ្ឋសភា រដ្ឋមន្ត្រី...»។

**មាត្រា ៧៧ កថាខណ្ឌទី ២** គួរតែត្រូវបានកែសម្រួលដូចតទៅ៖ "ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហរិញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី និងការយល់ព្រមពីរដ្ឋសភា........"

**មាត្រា ៧៨** គួរតែបន្ថែមកថាខណ្ឌថ្មីមួយដោយចែងថា "ដំណើរការលទ្ធកម្មសាធារណៈ ត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងធានានូវតម្លាភាព និងគណនេយ្យភាព ក្នុងដំណើរការនេះចាប់ពីការដេញថ្លៃជាសាធារណៈ រហូតដល់ការអនុវត្ត និងការត្រួតពិនិត្យ"។

**មាត្រា ៩៥** គួរតែបន្ថែម កថាខណ្ឌថ្មីមួយដោយចែងថា៖ «រាល់ការរកឃើញ និងអនុសាសន៍សំខាន់ៗ ត្រូវផ្តល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកែលម្អការអនុវត្តផែនការសមិទ្ធកម្ម និងសកម្មភាពតាមដាននៅឆ្នាំបន្ទាប់។»

**មាត្រា ១០០** គួរតែត្រូវបានបន្ថែមកថាខណ្ឌថ្មីមួយ ដោយចែងថា "របាយការណ៍អធិការកិច្ចហិរញ្ញវត្ថុដែលរួមបញ្ចូលការរកឃើញ និងអនុសាសន៍ ត្រូវបានពិនិត្យ និងសម្រេចដោយគណៈកម្មការទី ២ នៃរដ្ឋសភា"។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងដាក់បញ្ចូលនូវមតិយោបល់សំណើរកែលម្អចូលទៅក្នុងសេចក្តីព្រាងច្បាប់ថ្មីស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ។

យើងខ្ញុំក៏សូមអរគុណផងដែរចំពោះដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងឡាយ ដែលបានកំពុងចូលរួមផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសំរាប់ដំណើរការកំណែរទម្រង់។

យើងខ្ញុំសូមជូនពរ ឯកឧត្តម លោក ជំទាវ អស់លោក លោកស្រី និងអ្នកនាងកញ្ញា អោយជួយតែពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងជៀសផុតពីជម្ងឺកូវីដ១៩។

**សូមអរគុណ**!

បញ្ជីឈ្មោះក្រុមការងារវេទិកា នៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ

១. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
២. អង្គការតម្លាភាពកម្ពុជា
៣. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
៤. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
៥. អង្គការស្តារកម្ពុជា
៦. ក្រុមប្រឹក្សាយុវជនកម្ពុជា
៧. អង្គការអាក់សិនអេតកម្ពុជា
៨. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន
៩. អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
១០. គណកម្មការសម្របសម្រួលសកម្មភាពសុខភាព
១១. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា
១២. អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា
១៣. អង្គការអុកស្វាមកម្ពុជា
១៤. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
១៥. អង្គការសីលការ
១៦. អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព
១៧. អង្គការទិន្នន័យអំពីការអភិវឌ្ឍ
១៨. អង្គការភ្លែនអន្តរជាតិកម្ពុជា
១៩. អង្គការទស្សនៈពិភពលោក
២០. អង្គការ Save the Children International